ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ជ.ធ.ន.ឧ.
លេខ 2616
ចុះថ្ងៃ 02.06.22
ម៉ោង ....

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ : ៤១៣ សជណ

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង**

**កម្មវត្ថុ** ៖ ករណីសំណើសុំកែសម្រួលចំណុចព្រំនៃដែនព្រៃលិចទឹកបឹងទន្លេសាប ក្នុងភូមិសាស្ត្រស្រុកឯកភ្នំ ខេត្តបាត់ដំបង។

**យោង** ៖
- លិខិតលេខ១៣៣៦ ដនស/អសដក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ២៦៣ ខន/០២២ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចកែសម្រួលព្រំតំបន់៣ ក្នុងភូមិសាស្ត្រឃុំព្រែកហ្លួង ឃុំព្រែកនរិន្ទ និងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដោយកាត់ចេញដីទំហំ ៤០២ហិកតា ៤០អា ពីតំបន់៣ មកក្នុងតំបន់២ ស្របតាមនិយាមកាដែលបានឯកភាពរវាងក្រុមការងារក្រសួងធនធានទឹក និងឧតុនិយមជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មុនពេលធ្វើអនុក្រឹត្យ ដូចមានផែនទីនិងតារាងនិយាមកាភ្ជាប់មកជាមួយ និងប្រគល់ដីដែលបានពីការកែសម្រួលព្រំនេះ ជូនប្រជាពលរដ្ឋចំនួន ១៩១គ្រួសារ ប្រើប្រាស់និងអាស្រ័យផល ដូចខាងក្រោម៖

១- ឃុំព្រែកហ្លួង ដីទំហំ ១៨២ហិកតា ៣១អា ជូនប្រជាពលរដ្ឋចំនួន ១២៤គ្រួសារ។
២- ឃុំព្រែកនរិន្ទ ដីទំហំ ១៥២ហិកតា ៦៤អា ជូនប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ។
៣- ឃុំពាមឯក ដីទំហំ ៦៧ហិកតា ៤៥អា ជូនប្រជាពលរដ្ឋចំនួន ៩គ្រួសារ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរទន្លេសាប
- រដ្ឋបាលជលផល
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១០ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួលព្រំតំបន់៣ នៃតំបន់បឹងទន្លេសាប ក្នុងភូមិសាស្ត្រឃុំព្រែកហ្លួង ឃុំព្រែកនរិន្ទ និងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ ._**

កែសម្រួលព្រំតំបន់៣ នៃបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រឃុំព្រែកហ្លួង ឃុំព្រែកនរិន្ទ និងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋចំនួន ១៩១ គ្រួសារ បានបន្តប្រើប្រាស់ និងអាស្រ័យផល ក្នុងនោះ ៖

១.ឃុំព្រែកហ្លួង ដីទំហំ ១៨២ហិកតា ៣១អា ជូនប្រជាពលរដ្ឋចំនួន ១២៤គ្រួសារ។

២.ឃុំព្រែកនរិន្ទ ដីទំហំ ១៥២ហិកតា ៦៤អា ជូនប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ។

៣.ឃុំពាមឯក ដីទំហំ ៦៧ ហិកតា ៤៥ អា ជូនប្រជាពលរដ្ឋចំនួន ៩គ្រួសារ។

**មាត្រា២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរទន្លេសាប និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ